# សាស្ត្រាចារ្យខ្មែរបង្ហាញសមត្ថភាពលើកដំបូងក្នុងការបង្រៀនដល់និស្សិតបរទេស

**សៀមរាបៈ** ក្រុមសាស្ត្រាចារ្យវេជ្ជបណ្ឌិតកម្ពុជាបានបង្ហាញសមត្ថភាពរបស់ខ្លួនតាមរយៈការបង្រៀនដល់និស្សិតបរទេស នៅមន្ទីរពេទ្យជ័យវរ្ម័នទី៧ ដែលវគ្គបណ្តុះបណ្តាលថ្នាក់ក្រោយឧត្តមសិក្សានេះ មានរយៈពេល៥ថ្ងៃ ចាប់ផ្តើមពីថ្ងៃទី៣១តុលា ដល់ថ្ងៃទី៤ វិច្ឆិកា។




*លោកសាស្ត្រាចារ្យ Beat Richner - និស្សិតខ្មែរ និងស្វីស នៅក្នុងថ្ងៃបើកវគ្គបណ្តុះបណ្តាលថ្នាក់ក្រោយឧត្តមសិក្សា ដែលនិស្សិតកម្ពុជា និងស្វីស ចូលរួម*

វគ្គបណ្តុះបណ្តាលនេះមាន និស្សិតខ្មែរចំនួន១០០នាក់ និងនិស្សិតមកពីប្រទេសស្វីសចំនួន ៩០នាក់ចូលរួម។ ការបណ្តុះបណ្តាលនេះត្រូវចំណាយប្រាក់៣០០.០០០ដុល្លារ ដែលការចំណាយភាគច្រើនចំណាយទៅលើនិស្សិតស្វីស ដែលពួកគេទទួលបានសំបុត្រយន្តហោះឥតគិតថ្លៃ។ ថ្លៃស្នាក់នៅហូបចុកផ្តល់កម្រៃនិងការស្នាក់នៅដល់និស្សិតខ្មែរ រួមទាំងចំណាយទៅលើ" សាស្ត្រាចារ្យ និងវេជ្ជបណ្ឌិតដែលចូលរួមធ្វើការបង្រៀន។

លោកសាស្ត្រាចារ្យ បេអាត រីចនើ Beat Richner ប្រធានមូលនិធិគន្ធបុប្ផាបានមានប្រសាសន៍ឱ្យដឹងថា "ខ្ញុំពិតជាមានមោទនភាពណាស់ដែលសាស្ត្រាចារ្យ និងវេជ្ជបណ្ឌិតខ្មែរដែលជាអ្នកធ្វើការព្យាបាល និងពិនិត្យជំងឺនៅទីនេះមានសមត្ថភាពបង្រៀនដល់និស្សិតបរទេស។ លោកបន្តថា "ក្រោយការពិនិត្យឯកសារបង្រៀន ខ្ញុំឃើញថាវាមានប្រយោជន៍ និងមានមេរៀនល្អៗណាស់"។

តើវគ្គបណ្តុះបណ្តាលនេះ នឹងផ្តល់ជូននិស្សិតនូវលក្ខណៈពិសេសអ្វីខ្លះ លោកសាស្ត្រាចារ្យ បានមានប្រសាសន៍ឱ្យដឹងថា វគ្គបណ្តុះបណ្តាលនេះ យើងនឹងបង្ហាញពីរបៀបនៃការសាងសង់ និងដំណើរការមន្ទីរពេទ្យ ដែលធ្វើការព្យាបាលដោយឥតគិតថ្លៃចំណាយថវិកាតិច និងព្យាបាលកុមារបានក្នុងចំនួនដ៏ច្រើននេះដោយរបៀបណា។ យើងចង់បង្ហាញថាប្រព័ន្ធបែបនេះ យើងអាចធ្វើបាននៅក្នុងពិភពលោក ។

លោកសាស្ត្រាចារ្យ Beat Richner បានបន្តថា រយៈពេល៥ថ្ងៃនេះ យើងនឹងបង្ហាញពួកគេពីប្រព័ន្ធព្យាបាលនៅមន្ទីរពេទ្យនេះ មិនមានអំពើពុករលួយនិងមិនមានការរើសអើងអ្នកក្រីក្រនោះទេ ។ យើងក៏នឹងបង្រៀននិស្សិតទាំងនេះ ពីរបៀបនៃការកើតមានជំងឺឆ្លងក្នុងប្រទេសកម្ពុជា និងភាពស៊ាំរបស់យើងទប់ទល់នឹងជំងឺ ព្រោះក្មេងកើតជំងឺកាលណាយើងព្យាបាលជាសះស្បើយរួចហើយ នឹងមិនឆ្លងជំងឺដដែលនេះទៀតទេ ដោយសារវាមានភាពស៊ាំដែលផ្ទុះក្នុងខ្លួនក្មេង ផ្ទុយពីការយល់ច្រឡំពីក្រុមគ្រូពេទ្យនៅអឺរ៉ុបដែលថាការព្យាបាលជំងឺជាសះស្បើយរួចហើយជំងឺនោះ នឹងឆ្លងមកអ្នកជំងឺដដែលនោះម្តងទៀត ។

លោកសាស្ត្រាចារ្យ Beat Richner បានមានប្រសាសន៍ថា វគ្គបណ្តុះបណ្តាលនេះក៏ផ្តោតពីរបៀបធ្វើរោគវិនិច្ឆ័យថា តើត្រូវរករោគវិនិច្ឆ័យយ៉ាងម៉េចតាមរយៈការប្រើប្រាស់សម្ភារៈដ៏ទំនើបដែលមានក្នុងមន្ទីរពេទ្យនេះ និងហេតុអ្វីបានជាយើងត្រូវប្រើប្រាស់សម្ភារៈដ៏ទំនើបបែបនេះ និងពីរបៀបប្រើប្រាស់សម្ភារៈបែបណា ធ្វើមន្ទីរពិសោធន៍បែបណាមានទំហំប៉ុនណា និងគុណភាពយ៉ាងដូចម្តេច? លោកបន្តថាយើងនឹងបង្ហាញដល់និស្សិតពីស្ថានភាពអ្នកជំងឺ ដែលចូលមកសម្រាកព្យាបាលផងដែរពិសេសគឺបង្រៀនពួកគេទាំងទ្រឹស្តី និងការអនុវត្តន៍ផ្ទាល់។

លោកសាស្ត្រាចារ្យបានបន្តថា "ចំណុចខ្លាំងរបស់យើង គឺយើងត្រូវដំណើរការមន្ទីរពេទ្យ ដែលគ្មានអំពើពុករលួយព្រោះបើយើងព្យាបាលអ្នកជំងឺដោយត្រឹមត្រូវដោយមិនលួចថ្នាំរបស់អ្នកជំងឺ នោះគឺជាការបំបាត់អំពើពុករលួយហើយ"។ លោកបន្ថែមថា "បើមានអំពើពុករលួយក្នុងមន្ទីរពេទ្យ អនាម័យក្នុងពេទ្យក៏គ្រេចដែរ។ បើមន្ទីរពេទ្យមិនមានអនាម័យទេ មន្ទីរពេទ្យក្លាយជាកន្លែងចម្លងជំងឺ"។

លោកបន្តថា ឆ្នាំនេះយើងឃើញមានការឆ្លងជំងឺ មកកុមារពីតាមមន្ទីរពេទ្យនានាទៀត ហើយដោយសារការបង្កើតទារកមិនបានត្រឹមត្រូវការចាក់មិនមានអនាម័យនិងត្រឹមត្រូវនាំឱ្យនាំឱ្យកើតអាប់សែ និងឆ្លងមេរោគផ្សេងៗដល់កុមារ។ លោកបន្តថា ករណីឆ្លងជំងឺពីមន្ទីរពេទ្យបែបនេះ មិនមែនមាននៅតែកម្ពុជាទេ គឺមានទាំងនៅប្រទេសស្វីស ទាំងនៅទ្វីបអាហ្វ្រិក និងទ្វីបដទៃទៀត ប្រសិនបើពួកគេមិនបានយកចិត្តទុកដាក់លើបញ្ហាអនាម័យទេនោះ ។ ហេតុនេះយើងយើងនឹងប្រាប់ក្រុមនិស្សិតទាំងនោះថាបើចង់បើកមន្ទីរពេទ្យគួរត្រូវធ្វើយ៉ាងណាដើម្បីកុំឱ្យចម្លងមេរោគបន្ថែមទៅអ្នកជំងឺ ។

លោកសាស្ត្រាចារ្យយក់ សុផាន់ណា សកលវិទ្យាធិការនៃសកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាលបាន មានប្រសាសន៍ថាការងារបណ្តុះបណ្តាលជាការងាររបស់សាកលវិទ្យាល័យ ហើយដើម្បីការបណ្តុះបណ្តាលមានគុណភាពទាមទារឱ្យមានការចុះកម្មសិក្សានៅតាមមន្ទីរពេទ្យនិងវគ្គបណ្តុះបណ្តាលបន្តជាច្រើនទៀត ។ និស្សិតខ្មែរដែលចូលរួមវគ្គបណ្តុះបណ្តាលនេះជាកម្រិតថ្នាក់ ក្រោយឧត្តមសិក្សា ដែលពួកគេអាចបង្កើនចំណេះដឹងបន្ថែមទៀត។ វគ្គ បណ្តុះបណ្តាលបែបនេះ ពិតជាមានសារសំខាន់សម្រាប់បង្កើនចំណេះដឹងដល់និស្សិតទាំងខ្មែរ និងបរទេស ។

កញ្ញាអេសធឺ ណូកុមEsther Neukomm និស្សិតមកពី University of Basel ប្រទេសស្វីសបានបង្ហាញចំណាប់អារម្មណ៍របស់ខ្លួនថា វគ្គបណ្តុះបណ្តាលនេះមានសារសំខាន់ណាស់ ព្រោះយើងអាចដឹងពីអ្វី ដែលលោកសាស្ត្រាចារ្យBeat Richner បានធ្វើនិងអ្វីដែលជាការអភិវឌ្ឍន៍នៅមន្ទីរពេទ្យនេះលើផ្នែកវេជ្ជសាស្ត្រ និងរបៀបការព្យាបាលជំងឺនៅទីនេះ ក្នុងចរន្តវប្បធម៌ខុសគ្នាក្នុងទីនេះនៅអាហ្វ្រិក និងនៅប្រទេសស្វីស ។

កញ្ញាបន្តថា "វាមិនត្រឹមតែយើងអាចរៀនពីវប្បធម៌ប្លែកៗគ្នានោះទេ ប៉ុន្តែយើងអាចរៀនពីទ្រឹស្តី និងការព្យាបាលជំងឺនៅកម្ពុជានិងមុខជំងឺផ្សេងដែលមានភាពប្លែកគ្នាផងដែរ"។ **ប្រាយ ចំណាន**